ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ០៦៦/២១ រសក

# របាយការណ៍ខែកុម្ភៈ
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅខែមីនា ឆ្នាំ២០២១

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះបីជាបាននិងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តថ្មីដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងស្ថានភាពប្រែប្រួលនៃសេដ្ឋកិច្ចពិភពលោក និងបន្ថែមដោយវិបត្តិនៃការរាតត្បាតដោយជំងឺកូវីដ១៩។

ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត បានបន្តទិសដៅការងារ ផ្តោតការយកចិត្តទុកដាក់បន្ថែម ទៅលើបញ្ហាវិបត្តិកូវីដ១៩ ដែលជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ និងត្រូវបន្ថែមភារកិច្ច ក្នុងការដោះស្រាយទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសអ្នកដែលវិលត្រឡប់ពីប្រទេសក្រៅ ដែលមានចំនួនច្រើនលើសលប់ និងភាគច្រើន ជាអ្នកដែលខ្វះលទ្ធភាព ក្នុងការទ្រទ្រង់ជីវភាព ហើយងាយរងគ្រោះ។ ការជួយសង្គ្រោះពលករដែលវិលត្រឡប់មកពីក្រៅប្រទេស គឺជាកិច្ចការចាំបាច់ ដើម្បីបង្ការទប់ស្កាត់ ការនាំចូលជំងឺកូវីដ១៩ ទៅក្នុងសហគមន៍ និងការដោះស្រាយភាពប្រឈមក្នុងពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ព្រមទាំងទប់ស្កាត់ការចាញ់បោកមេខ្យល់ ក្នុងការនាំពលករត្រឡប់ទៅប្រទេសគោលដៅវិញ ក្នុងស្ថានភាពដែលមានការរឹតបន្តឹងពីប្រទេសគោលដៅ ដើម្បីការពារជំងឺរាតត្បាត និងវិបត្តិសេដ្ឋកិច្ចដែលកើតមានទូទាំងពិភពលោក ដែលធ្វើឱ្យពលករខាតបង់រឹតតែធ្ងន់ធ្ងរ និងធ្លាក់ទៅក្នុងរលកថ្មីនៃអំពើជួញដូរមនុស្ស។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាពជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោមៈ

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"ការពពោះជំនួស"។
- ក្រសួងយុត្តិធម៌ ៖
  - រដ្ឋសភាបានអនុម័តច្បាប់ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" (MLA) (ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការណ៍ជាប្រញាប់ ដោយព្រះរាជក្រមលេខ នស/រកម ០៦២០/០២០ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០)។
  - បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

#### ក.២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "ការបញ្ជូនទណ្ឌិត"។

#### ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។

#### ក.៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

#### ក.៥ ការពង្រឹងកិច្ចសហប្រតិបត្តិការ

- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំ និងចូលរួមអនុវត្តគម្រោងរួមគ្នា រវាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ សម្រាប់ពលករវិលត្រឡប់ ក្នុងដំណាក់កាល នៃការរាតត្បាតដោយជំងឺកូវីដ១៩ នៅក្នុងខេត្ត បាត់ដំបង សៀមរាប និងបន្ទាយមានជ័យ ។

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

##### ខ.១.១. ការអប់រំដោយផ្ទាល់

នៅក្នុងខែកុម្ភៈ ឆ្នាំ២០២១នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន

៩.៩១០លើក មានអ្នកចូលរួមសរុបចំនួន ៤៦៤.៣៦០នាក់ (ធៀបនឹងខែមករា មានចំនួន ៤៨៤.៣០១នាក់ គឺមានការថយចុះចំនួន១៩.៩៤១នាក់  ក្នុងនោះស្ត្រីចំនួន ២៥១.៧៧៥នាក់ ស្មើនឹង៥១,៩៨% ដូចមានតារាងលម្អិតខាងក្រោម៖

## តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន / រាជធានី-ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៧៥៥ | ៥៥.២៩៤ | ៣៣.១៦៩ | ១១៥ | ១០.៩០២ | ៥.១០៨ |
| | សរុប ក្រសួង ស្ថាប័ន | ៧៥៥ លើក | ៥៥.២៩៤ នាក់ | ៣៣.១៦៩ នាក់ | ១១៥ លើក | ១០.៩០២ នាក់ | ៥.១០៨ នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្ដាល | ៥៦១ | ១៤.៧៨៩ | ៨.០០៦ | ៨៧៩ | ៥០.៩៩៧ | ២២.១៣១ |
| ៣ | ខេត្តបាត់ដំបង | | | | | | |
| ៤ | ខេត្តពោធិ៍សាត់ | ២៩៤ | ១៦.០៧២ | ៦.៧៧៥ | ១០៥ | ៦.៤៨៩ | ២.៩០៤ |
| ៥ | ខេត្តសៀមរាប | ៥៦៩ | ២២.៧៨៥ | ១៣.៦៣៧ | ១៥៨ | ៤.៤២៧ | ២.៤៩៩ |
| ៦ | ខេត្តកំពង់ឆ្នាំង | ១៣១៥ | ៤០.៣៣៨ | ២១.៣៦៦ | ៨៣២ | ២០.៨២៩ | ១០.៨៦៩ |
| ៧ | ខេត្តកំពង់ចាម | ២.២០៧ | ១១៧.៧២៩ | ៦៩.៤១៨ | ១.១៦៩ | ៥៧.៥១៨ | ៣៣.៣០៦ |
| ៨ | ខេត្តព្រះសីហនុ | | | | | | |
| ៩ | ខេត្តព្រះវិហារ | ១ | ៤៤ | ៣៥ | | | |
| ១០ | ខេត្តស្វាយរៀង | ៣២៨ | ១០.៨៩៣ | ៥.៩០៤ | | | |
| ១១ | ខេត្តប៉ៃលិន | | | | | | |
| ១២ | ខេត្តកោះកុង | | | | ៥៤ | ១.១០១ | ៦៣១ |
| ១៣ | ខេត្តកំពត | ៧៩ | ១.៦៩២ | ៩០៦ | | | |
| ១៤ | ខេត្តកំពង់ធំ | | | | | | |
| ១៥ | ខេត្តតាកែវ | ៣៤២ | ១៧.១៨៦ | ៧.៩៦០ | ៧២ | ២.៧០១ | ១.២៨៤ |
| ១៦ | ខេត្តក្រចេះ | ៥៣ | ៦.៣៧១ | ៣.១៧៩ | | | |
| ១៧ | ខេត្តកែប | ១៣ | ៣.៤៩៩ | ១.៤៨៥ | | | |
| ១៨ | ខេត្តកំពង់ស្ពឺ | ២ | ១០១ | ១៧ | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | | | | | | |
| ២២ | ខេត្តត្បូងឃ្មុំ | ១ | ១.៥៧៤ | ៨៧៩ | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | ៤ | ៩៤៨ | ២៥៧ |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | ២ | ៨១ | ៥០ | | | |
| | សរុប រាជធានី-ខេត្ត | ៥.៧៦៧លើក | ២៥៣.១៥៤នាក់ | ១៣៩.៦១៧នាក់ | ៣.២៧៣លើក | ១៤៥.០១០នាក់ | ៧៣.៨៨១នាក់ |
| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន ៩.៩១០ លើក | | ចំនួនមនុស្សសរុប ៤៦៤.៣៦០ នាក់ | | ចំនួនស្ត្រី ២៥១.៧៧៥ នាក់ | |

### ខ.១.២. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ APLE បើកកម្មវិធីយុទ្ធនាការ ស្តីពីយុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត និងលើកកម្ពស់សីលធម៌ ដើម្បីសុវត្ថិភាពសង្គម ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅវិទ្យាស្ថានជាតិអប់រំ អ្នកចូលរួមមាន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ សរុបប្រមាណ ២៥០នាក់។

### ខ.១.៣. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

| សកម្មភាព | លទ្ធផល |
|---|---|
| **ខេត្តសៀមរាបៈ** មន្ទីរព័ត៌មានខេត្ត បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុជាតិនគរភ្នំ FM១០៣MHz និងទូរទស្សន៍ជាតិខេត្តសៀមរាប ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស។ | តាមវិទ្យុ ៥៦ លើក (ផ្សាយផ្ទាល់ ២៣លើក និងចាក់ផ្សាយឡើងវិញ ៣៣លើក) |
| **ខេត្តមណ្ឌលគិរីៈ** មន្ទីរធម្មការ និងសាសនាខេត្ត បានធ្វើការផ្សព្វផ្សាយបញ្ញាប តាមវិទ្យុ FM៩៧MHz ក្នុងកម្មវិធី ព្រះពុទ្ធសាសនាផ្សាភ្ជាប់សង្គម ចំនួន ២០ថ្ងៃក្នុង១ខែ។ | តាមវិទ្យុ ២០ លើក |
| **ខេត្តតាកែវៈ** មន្ទីរព័ត៌មានខេត្ត បានធ្វើការផ្សព្វផ្សាយច្បាប់នានា ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈវិទ្យុគោកធ្លក និងទូរទស្សន៍គោកធ្លក។ | តាមវិទ្យុ និងទូរទស្សន៍ ១២១លើក |
| សរុប | តាមវិទ្យុ និងទូរទស្សន៍ ១៩៧ លើក |

### ខ.១.៤. ការចូលរួមជាវាគ្មិន ក្នុងកម្មវិធីនានា

| សកម្មភាព | ចំនួនលើក |
|---|---|
| - **ខេត្តកំពង់ចាមៈ** ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុ ស្តីពីការលើកទឹកចិត្ត ឱ្យមាននគរបាលជាស្ត្រីនៅតាមមូលដ្ឋាន និងការទប់ស្កាត់ភាពមិនប្រក្រតី ក្នុងទិវាបុណ្យនៃក្តីស្រឡាញ់។ | ០១លើក |
| សរុប | ០១លើក |

## ខ.២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ខ.២.១. ការធ្វើអធិការកិច្ច និងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ

- ក្រុមការងារការិយាល័យនីតិកម្ម និងអធិការកិច្ច បានចុះអធិការមជ្ឈមណ្ឌលរបស់អង្គការដែលមានកិច្ចព្រមព្រៀងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមណ្ឌលសំចតសរុបចំនួន ១៨មណ្ឌល (មជ្ឈមណ្ឌលរបស់អង្គការមាន ១៧មណ្ឌល និងមណ្ឌលសំចតប៉ោយប៉ែតរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះចំនួន ០១) ដែលមានទីតាំងស្ថិតនៅ រាជធានីភ្នំពេញ ខេត្តសៀមរាប បាត់ដំបង និងខេត្តបន្ទាយមានជ័យ ចាប់ពីថ្ងៃទី ០១ ដល់ថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០២១។
- **ខេត្តប៉ៃលិនៈ** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ នៅតាមគ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា សៃឡូ កាស៊ីណូ ឡតជ្ជ និងអាហារដ្ឋានចំនួន ៨០កន្លែង ដោយរកពុំឃើញមានការកេងប្រវ័ញ្ច និងអំពើជួញដូរកម្លាំងពលកម្មទេ។

ខ.២.២. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- អគ្គស្នងការដ្ឋាននគរបាលជាតិ

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពទិន្នន័យប្រចាំខែ ចំពោះពលករចំណាកស្រុកត្រឡប់មកពីក្រៅប្រទេសវិញ ទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន ១០៨.៦១៦នាក់ (ស្រី ៤៧.២២៨នាក់) អនីតិជន២.៥១៩នាក់។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បាត់ដំបង និងខេត្តតាកែវ បានធ្វើការងារបង្ការ ទប់ស្កាត់ពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកទៅក្រៅប្រទេស ដោយខុសច្បាប់បានចំនួន ០៩លើក មនុស្សចំនួន ១៦០នាក់ (ស្រី ២៥នាក់) សមត្ថកិច្ចបានធ្វើកិច្ចសន្យាអប់រំ ណែនាំ រួមឱ្យត្រឡប់ទៅផ្ទះវិញ។

ខ.២.៣. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

- អគ្គស្នងការដ្ឋាននគរបាលជាតិ

- ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ កំពង់ធំ ក្រចេះ ស្ទឹងត្រែង ពោធិ៍សាត់ រតនៈគិរី និងខេត្តតាកែវ បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ចំនួន ១១២លើក។
- ស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ និងខេត្តកែប បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម និងផ្សព្វផ្សាយ ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ភោជនីយដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ ម៉ាស្សា ចំនួន ២០គោលដៅ មនុស្សចូលរួម ១៥៣នាក់ (ស្រី ១២៩នាក់)។

ខ.២.៤. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

- ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចំនួន ៤៦គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ និងបានប្រមូលព័ត៌មានពីសុខទុក្ខនារីខែដែលរៀបការ ទៅរស់នៅក្រៅប្រទេសតាមរយៈការទំនាក់ទំនងតាមទូរស័ព្ទចំនួន ០៤នាក់(ប្រទេសកូរ៉េ) មានសេចក្តីសុខសប្បាយជាធម្មតា។

## ខ.៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- ខេត្តព្រះសីហនុ៖ បន្តសហការជាមួយអង្គការម្លប់តាប៉ាង ធ្វើការទំនាក់ទំនងជាប្រចាំជាមួយបណ្តាញដែលបានដាក់ចំនួន ១.២២៧នាក់ (ម៉ូតូឌុប ក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍) ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។
- ខេត្តក្រចេះ៖ កុមារមករស់នៅភូមិកុមារកម្ពុជា SOS សរុបចំនួន ៨៩នាក់ (ស្រី ៣៩នាក់) និងមន្ទីរសង្គមកិច្ចខេត្ត បានចុះអធិការកិច្ចចំនួន ០២លើក។
- ខេត្តពោធិ៍សាត់៖ មានមណ្ឌលកុមាររដ្ឋ ០១ កុមារចំនួន ០៧នាក់ (ស្រី ០៤នាក់) និងមណ្ឌលកុមារអង្គការ ១២ កុមារចំនួន ១៧៦នាក់ (ស្រី ៧៩នាក់)។
- ខេត្តកែប៖ មានមណ្ឌលកុមារ ០១ កុមារចំនួន ៤៧នាក់ (ស្រី ១៧នាក់)។
- ខេត្តព្រះវិហារ៖ មានមណ្ឌលកុមាររដ្ឋ ០១ កុមារចំនួន ៩៧នាក់ (ស្រី ៤០នាក់) និងមណ្ឌលកុមារអង្គការ ០៦ កុមារចំនួន ១៦០នាក់ (ស្រី ៧៩នាក់)។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ៣៩ករណី(ធៀបនឹងខែមករា មានចំនួន ១៥ករណី កើនឡើងចំនួន ២៤ករណី)ស្មើនឹង១៦០% ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ៥៤នាក់ (ស្រី ០៨នាក់) មានជនជាតិវៀតណាម ០១នាក់ ក្នុងនោះជនសង្ស័យជាអនីតិជន ០២នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន ១៥៥នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ១៣នាក់ អាយុ១៥-១៧ឆ្នាំ ១២នាក់ និងអាយុពី១៨ឆ្នាំឡើង ១៣០នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ១៣នាក់ និងប្រគល់ឱ្យគ្រួសារ ១៤២នាក់) ក្នុងនោះមានចែកជាៈ

**១. ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន ២៧ករណី/០២ករណី (កើនឡើង ២៥ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ៤២នាក់ (ស្រី ០៦នាក់) មានជនជាតិវៀតណាម ០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ១៣៥នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ០៣នាក់ អាយុ១៥-១៧ឆ្នាំ ០៦នាក់ និងអាយុ១៨ឆ្នាំឡើង ១២៦នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ០៣នាក់ និងប្រគល់ឱ្យគ្រួសារ ១៣២នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០១ | ០៣ | ០២ | វៀតណាម១ |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ២៥ | ១៣១ | ៣៨ | |
| -អំពើលក់ដូរមនុស្ស | ០១ | ០១ | ០២ | |
| *សរុប* | *២៧ ករណី* | *១៣៥ នាក់* | *៤២ នាក់* | *០១ នាក់* |

**២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន ១២ករណី/១៣ករណី (ថយចុះ ០១ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១២នាក់ (ស្រី ០២នាក់) អនីតិជន ០២នាក់។ សង្គ្រោះជនរងគ្រោះចំនួន ២០នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ១០នាក់ អាយុ១៥-១៧ឆ្នាំ ០៦នាក់ និងអាយុ១៨ឆ្នាំឡើង ០៤នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ១០នាក់ និងប្រគល់ឱ្យគ្រួសារ ១០នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០១ | ០៧ | ០១ |
| -ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ០១ | ០៣ | ០១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ១០ | ១០ | ១០ (អនី.២) |
| *សរុប* | *១២ នាក់* | *២០ នាក់* | *១២ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសនានា សរុបចំនួន ៨.២៧៨នាក់ (ស្ត្រី ៣.៣៩៥នាក់) កុមារ ៧៨៣នាក់ (កុមារី ៤០០នាក់) ដូចមានខាងក្រោមនេះ៖

- ក្រុមការងារការពារជនរងគ្រោះ ទទួលពីប្រទេសនានា សរុបចំនួន ៦១នាក់ (ស្ត្រី ៤៩នាក់) មកពីប្រទេសចិន ៤៣នាក់ វៀតណាម(ឆ្លងទៅចិន) ០៣នាក់ ឥណ្ឌូនេស៊ី ០២នាក់ និងប្រទេសម៉ាឡេស៊ី ១៣នាក់ ជាករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម ១២នាក់ អាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ ៣១នាក់ និងករណីងាយរងគ្រោះ ១៨នាក់ បានធ្វើការសម្ភាសន៍រួចបញ្ជូនទៅទទួលសេវានៅអង្គការដៃគូ។
- មណ្ឌលសំចតប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ បានទទួលជនចំណាកស្រុក ដែលអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ៨.២១៧នាក់ (ស្ត្រី ៣.៣៤៦នាក់) កុមា ៧៨៣នាក់ (កុមារី ៤០០នាក់) និងបានធ្វើការសម្ភាសន៍ដើម្បីកំណត់អត្តរកមុខសញ្ញាជនរងគ្រោះ និងងាយរងគ្រោះ ចំនួន ០៨នាក់ ជាករណីងាយរងគ្រោះ និងបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ។

- ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

ស្នងការដ្ឋាននគរបាលខេត្ត បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងច្រកទ្វារព្រំដែនអន្តរជាតិ កម្ពុជា-វៀតណាម ចំនួន ១៩លើក មនុស្សចំនួន ៧៨នាក់(ស្រី ២០នាក់ អនីតិជន ១១នាក់) ក្នុងនោះមាន៖

| | | | | |
|---|---|---|---|---|
| - ខេត្តកោះកុង | ចំនួន ១៨លើក | មនុស្សចំនួន | ៧០នាក់ | (ស្រី ១៤នាក់) |
| | | អនីតិជនចំនួន | ០៨នាក់។ | |
| - ខេត្តស្វាយរៀង | ចំនួន ០១លើក | មនុស្សចំនួន | ០៨នាក់ | (ស្រី ០៦នាក់) |
| | | អនីតិជន | ០៣នាក់។ | |

### ឃ.២. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ឱ្យទៅសហគមន៍វិញ សរុបចំនួន ០៩នាក់ (ស្ត្រី) ជាករណីរំលោភបំពានផ្លូវភេទ ០២នាក់ និងអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ/បង្ខំ ០៧នាក់។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការងារបណ្តុះបណ្តាល

ក.១.១.ការបណ្តុះបណ្តាលក្នុងប្រទេស

តារាងវគ្គបណ្តុះបណ្តាល

| សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយអង្គការសកម្មភាពដើម្បីកុមារ បើកវគ្គបណ្តុះបណ្តាលជំនាញ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស នីតិវិធីអនីតិជនទំនាស់នឹងច្បាប់ និងការសម្ភាសន៍បែបកុមារមេត្រី។ | ០១ | ៣០ | ០៥ |
| ខេត្តត្បូងឃ្មុំ៖ ស្នងការដ្ឋាននគរបាលខេត្ត បានសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ បើកវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស និងក្រមសីលធម៌ ក្នុងការសម្ភាសន៍កំណត់អត្តសញ្ញាណជនរងគ្រោះ។ | ០១ | ៣៤ | ០៤ |
| សរុប | ០២ វគ្គ | ៦៤ នាក់ | ០៩ នាក់ |

### ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

#### ខ.១. ក្នុងប្រជុំក្នុងប្រទេស និងក្រៅប្រទេស

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖

- ដឹកនាំកិច្ចប្រជុំ ស្តីពី "ការកែសម្រួលរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ គ.ជ.ប.ជ ឆ្នាំ២០២០ និងលើកទិសដៅការងារ ឆ្នាំ២០២១" ចំនួន ០៣លើក អ្នកចូលរួមចំនួន ២៤នាក់ (ស្រី ០៥នាក់) នៅសាលប្រជុំ គ.ជ.ប.ជ ។
- ជាអធិបតីភាព ក្នុងកិច្ចប្រជុំស្ថាប័នមិនមែនរដ្ឋាភិបាល ប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា បញ្ហាប្រឈម និងទិសដៅអនាគត ដែលរៀបចំ និងសម្របសម្រួលពីអង្គការ USAID ដោយមានការអញ្ជើញចូលរួម ពីអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តំណាងពី បណ្តាអង្គការដៃគូពាក់ព័ន្ធនានា មានដូចជា Caritas swiss, IJM, IOM,A21, Cambodia Act, Hope for justice, Care, Ratanak, USAID, LSCW, We world-GVC ក្នុងកិច្ចការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសេវាគាំទ្រដល់ជនរងគ្រោះជាពលករទេសន្តប្រវេសន៍ និងនៅក្នុងប្រទេស នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ។
- ប្រជុំពិភាក្សាជាមួយថ្នាក់ដឹកនាំនៃរដ្ឋបាល ខេត្តបន្ទាយមានជ័យ ពាក់ព័ន្ធនឹងគម្រោងការផ្តល់សេវាគាំទ្រទៅកាន់ពលករដែលវិលត្រលប់ មានស្ត្រី និងកុមារដែលងាយរងគ្រោះ នៅសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ។
- ដឹកនាំកិច្ចប្រជុំពិភាក្សា តាមរយៈ Video Conference ស្តីពី "**REGIONAL PEER LEANING BUILDING ON COMMITMENTS TO COMBAT IUU FISHING AND TO**

PROVIDE HUMAN RIGHTS PROTECTION IN THE CAPTURE FISHERY SECTOR in SOUTH-EAST ASIA" ដែលរៀបចំដោយ The Coordinating Ministry for Maritime and Investment Affairs of Republic of Indonesia in collaboration with Foundation for International Human Rights Reporting Standards (FIHRRST) នៅសាលប្រជុំគ.ជ.ប.ជ។

- ដឹកនាំកិច្ចប្រជុំពិភាក្សា ស្តីពីការបង្កើតទស្សនាវដ្តីសម្រាប់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំ គ.ជ.ប.ជ។
- ដឹកនាំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញជាមួយលេខាធិការដ្ឋានអង្គការសហប្រជាជាតិ និងបណ្តាញអង្គការសហប្រជាជាតិ ស្តីពីទេសន្តរប្រវេសន៍ (UNNetworkMigration) ស្តីពីការដាក់បញ្ចូលកម្ពុជាទៅក្នុងបញ្ជីប្រទេសជ័យលាភី នៃការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាពរៀបរយ និងស្របច្បាប់ នៅសាលប្រជុំ គ.ជ.ប.ជ។

### ខ.២. សិក្ខាសាលា

- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានសហការជាមួយ ក្រសួងអប់រំ យុវជន និងកីឡា បើកសិក្ខាសាលា ស្តីពីការបំប៉នគ្រូឧទ្ទេសលើការអប់រំបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការប្រើប្រាស់សៀវភៅ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម ដោយមានការចូលរួមពីលោកគ្រូ អ្នកគ្រូមកពីសាលាគរុកោសល្យចំនួន៧ខេត្ត នៅសាលាគរុកោសល្យ និងវិក្រិដ្ឋការខេត្តកំពង់ចាម សរុបចំនួន ៨៦នាក់ (ស្រី២៣នាក់) ។

### ខ.៣. ការទទួលជួបពិភាក្សាការងារ

➢ ថ្នាក់ជាតិ៖

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានទទួលជួបពិភាក្សាការងារ ជាមួយក្រុមប្រឹក្សាជាតិដើម្បីកុមារ នៅសាលប្រជុំ គ.ជ.ប.ជ។

➢ ថ្នាក់ក្រោមជាតិ៖

- **ខេត្តសៀមរាប៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានដឹកនាំស្នងការដ្ឋាននគរបាលខេត្ត មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត មន្ទីរកិច្ចការនារីខេត្ត និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ទទួលជួបពិភាក្សាការងារ ជាមួយអង្គការ សង្គ្រោះដោគវាសនា ស្តីពីកិច្ចសហការលើការរួមគ្នាដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។
- **ខេត្តព្រៃវែង៖** លោកជំទាវ អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត
    - បានជួបសំណេះសំណាលការងារ និងសម្តែងការគួរសមជាមួយក្រុមការងារនៃអង្គការ បេសសកម្មយុត្តិធម៌អន្តរជាតិ ប្រចាំកម្ពុជា ស្តីពីភាពជាដៃគូក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
    - បានជំនួបពិភាក្សាការងារជាមួយអង្គការកុមារអាស៊ីប្រចាំកម្ពុជា អំពីដំណើរការនៃការគាំទ្រដល់មណ្ឌលកុមារកំព្រាខេត្ត។

### គ. ការខារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ៦៤លើក មានអ្នកចូលរួមសរុប ១.៤០៥នាក់ (ស្រី ៣១៩នាក់) ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ០៧លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន ៣៧លើក។ (ឧបសម្ព័ន្ធ១)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក. ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។

- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

**គ. សំណូមពរ**

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

**ឃ. សន្និដ្ឋាន**

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែមីនា ឆ្នាំ ២០២១

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដេកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ**)។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.........................ខែ..............ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ..........ឆ្នាំ២០២១

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ_ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៦៤លើក) មនុស្សចំនួន ១.៤០៥នាក់ (ស្រី ៣១៩នាក់)

| ស្ថាប័ន<br>សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញ<br>-បានចុះទៅជួបសំណេះសំណាលជាមួយក្រុមការងារធ្វើចត្តាលីស័ក នៅសាលាព្រហ្មនិមិត្ត សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។<br>-បានអញ្ជើញចូលរួមជាអធិបតីភាពក្នុងពិធីប្រគល់-ទទួល សម្ភារៈប្រើប្រាស់ចាំបាច់សម្រាប់ស្ត្រី និងកុមារ ក្នុងស្ថានភាពប្រឈមជំងឺកូវីដ១៩ ពីអង្គការអភិវឌ្ឍន៍ UNFP ខេត្តបន្ទាយមានជ័យ។<br>-បានអញ្ជើញធ្វើទស្សនៈកិច្ចក្នុងទីស្នាក់ការអង្គការ តំណក់ទឹក ដែលជាអង្គការធ្វើកិច្ចសហប្រតិបត្តិការផ្តល់សេវាផ្នែកអប់រំ វិជ្ជាជីវៈ ទៅកាន់កុមារដែលងាយរងគ្រោះ នៅខេត្តបន្ទាយមានជ័យ។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៊ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖<br>-កិច្ចប្រជុំបូកសរុបលទ្ធផល នៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារមានអាយុក្រោម២ឆ្នាំ និងកម្មវិធីឧបត្ថមសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ១៩ ក្នុងឆ្នាំ២០២០ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២១ នៅសណ្ឋាគារភ្នំពេញ។<br>-ដឹកនាំកិច្ចប្រជុំសម្របសម្រួល ស្តីពី ១.ការវាយតម្លៃលើកម្រងសំណួរលក្ខណៈវិនិច្ឆ័យប្រចាំឆ្នាំ២០២០ របស់រាជធានី-ខេត្ត ២.កិច្ចប្រជុំរៀបចំឯកសារបញ្ចប់អនុស្សរណៈយោគយល់គ្នា រវាងគណៈកម្មាធិកាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសមាគមន៍មូលនិធិ ឈាន ឆាយ ដើម្បីមនុស្សធម៌ ៣.កិច្ចប្រជុំត្រៀម រវាងគណៈកម្មាធិកាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការ WE WORLD ONLUS អ្នកចូលរួមចំនួន១០នាក់ ស្រី០១នាក់។<br>-សិក្ខាសាលាពិគ្រោះយោបល់ជាមួយកុមារ និងយុវជនក្នុងការអនុវត្តផែនការសកម្មភាពគោលនយោបាយជាតិ ស្តីពីប្រព័ន្ធការពារកុមារ ឆ្នាំ២០១៩ ដល់ឆ្នាំ២០២៩ នៅសណ្ឋាគារសាន់វ៉េភ្នំពេញ។<br>-ដឹកនាំសម្របសម្រួលសកម្មភាពពិនិត្យ និងបូកសរុបឯកសារនៃកិច្ចសហប្រតិបត្តិការ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយបណ្តាប្រទេសជាមិត្ត និងអង្គការដៃគូជាតិ អន្តរជាតិពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន០៥នាក់ ស្រី០១នាក់ នៅសាលប្រជុំ គ.ជ.ប.ជ។<br>-សិក្ខាសាលា ស្តីពីការអភិវឌ្ឍន៍សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ ឆ្នាំ២០២១ដល់ឆ្នាំ២០៣០ ក្រោមអធិបតីភាព ឯកឧត្តម ស៊ា ហួង រដ្ឋលេខាធិការក្រសួងសុខាភិបាល នៅសណ្ឋាគារប៉ាវ៉ាឌី ខេត្តសៀមរាប។<br>-ពិធីបិទកិច្ចពិភាក្សាអំពីផែនការយុទ្ធសាស្ត្រជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ នៅសណ្ឋាគារ ផាវ៉ាដាយអង្គរ ខេត្តសៀមរាប។ |

| | |
|---|---|
| | -ដឹកនាំបន្តពិនិត្យ និងកែសម្រួលខ្លឹមសារអនុស្សរណៈនៃការយោគយល់គ្នា រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការ WE WORLD ONLUS និងវាយតម្លៃកម្រងសំណួររាជធានី-ខេត្ត នៅសាលប្រជុំ គ.ជ.ប.ជ.។<br>-បិទអង្គសិក្ខាសាលា ស្តីពីការបំប៉នគ្រូឧទ្ទេសលើការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការប្រើប្រាស់សៀវភៅ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តកំពង់ចាម។<br>-កម្មវិធីប្រគល់-ទទួល សម្ភារៈបច្ចេកវិទ្យាអនឡាញសម្រាប់ប្រើប្រាស់ ក្នុងបន្ទប់ប្រជុំប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបើកវគ្គបណ្តុះបណ្តាលអនឡាញទ្វេភាគី រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ស្តីពីការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅសណ្ឋាគារសោមាទេវីអង្គរ ខេត្តសៀមរាប។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ១១ច្បាប់ លិខិតចូល ០១ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ១៤ច្បាប់ លិខិតចូល ១៨ច្បាប់។<br>- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។<br>- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែកុម្ភៈ ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បូកសរុបរបាយការណ៍ខែកុម្ភៈ ឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។<br>- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវីគី ៣៨សកម្មភាព។<br>- ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។<br>- ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ Wiki ncct Convert ជា PDF បានចំនួន១៥ច្បាប់។<br>▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**<br>- លោកប្រធានក្រុមជំនួយកិច្ចការ បានចូលរួមកិច្ចប្រជុំរៀបចំឯកសារបទបង្ហាញ សម្រាប់អង្គសិក្ខាសាលា ស្តីពីវគ្គបំប៉នគ្រូឧទ្ទេសថ្នាក់ជាតិ លើការប្រើប្រាស់សៀវភៅអប់រំ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន ក្រោមការដឹកនាំលោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា នៅសាលប្រជុំក្រសួងអប់រំ។<br>▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**<br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក **លី តុងហ៊ុយ** អគ្គលេខាធិការរង បានអញ្ជើញចូលរួម៖ |

| | |
|---|---|
| | ○ សិក្ខាសាលាពិគ្រោះយោបល់ ជាមួយកុមារ និងយុវជនលើសេចក្តីព្រាងផែនការ សកម្មភាពគោលនយោបាយជាតិ ស្តីពីប្រព័ន្ធការពារកុមារ ឆ្នាំ២០១៩ ដល់ឆ្នាំ ២០២៩ ក្រោមអធិបតីភាព លោកជំទាវ ខៀវ បូរី រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគារ សាន់វ៉េ រាជធានីភ្នំពេញ។<br>○ កិច្ចប្រជុំឆ្លងសេចក្តីព្រាងផែនការសកម្មភាព ស្តីពីការរៀបចំសន្ធានុក្រម បច្ចេកទេសសព្ទ ក្នុងវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ នៃក្រសួងមហាផ្ទៃ រយៈពេល២ឆ្នាំ (២០២១-២០២២) ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍សាស្ត្រាចារ្យ **សេង ផល្លី** ប្រធានបណ្ឌិត្យសភានគរបាលជាតិកម្ពុជា នៅសាលប្រជុំបណ្ឌិត្យសភានគរបាលជាតិកម្ពុជា ជីតជ្ក។<br>▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**<br>- លោកជំទាវ ឧត្តមសេនីយ៍ត្រី **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង បានអញ្ជើញចូលរួម៖<br>○ សម្របសម្រួលពិនិត្យ កែសម្រួល និងផ្តល់ជាតុចូលទៅក្នុងផែនការសកម្មភាពជាតិ ស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ឆ្នាំ២០១៩-២០២១ នៅសាលប្រជុំ គ.ជ.ប.ជ។<br>○ កិច្ចប្រជុំពិភាក្សាជាមួយលោក **អៀង ប៊ុនថន** អ្នកប្រឹក្សាយោបល់ និងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាល ដោយទទួលបានការអនុញ្ញាតចូលជំនួបពិភាក្សាជាមួយឯកឧត្តម **ហៃ ហ៊ុនឡេង** ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ ស្តីពីការរកដំណោះស្រាយ ឬក៏ជាគោលការណ៍ក្នុងការជួយជំរុញឱ្យពលករចំណាកស្រុក ដែលវិលត្រឡប់មកវិញ ដើម្បីទទួលបានការងារសមស្របធ្វើការនៅក្នុងស្រុក នៅសាលប្រជុំទីភ្នាក់ងារជាតិ។<br>○ ដឹកនាំកិច្ចប្រជុំក្រុមជំនួយកិច្ចការ ស្តីពីការរៀបចំតារាងបច្ចុប្បន្នភាព ព័ត៌មាន អនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងនានា តាមទម្រង់មួយដែលត្រូវបានផ្តល់ឱ្យក្រសួងមហាផ្ទៃ នៅសាលប្រជុំ គ.ជ.ប.ជ។<br>○ កិច្ចប្រជុំលើកទី១ ស្តីពីក្រុមការងារទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន ក្នុងក្របខណ្ឌអាស៊ាន ក្រោមអធិបតីភាពឯកឧត្តម **ផាត សុផានិត** នៅក្រសួងមហាផ្ទៃ។<br>▪ **ក្រុមជំនួយកិច្ចការទេន្តរប្រវេសន៍**<br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ខៀវ ចាន់រ៉ា** អគ្គលេខាធិការរង បានអញ្ជើញចូលរួមកិច្ចប្រជុំជាមួយគណៈកម្មាធិការប្រឹក្សាគ្រោង ស្តីពីការពិនិត្យ និងរៀបចំផែនការសកម្មភាពបន្ត សម្រាប់អនុវត្តគម្រោ ILI-Triangle ឆ្នាំ២០២០ ដោយរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមអធិបតីភាព ឯកឧត្តម **ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ នៅសណ្ឋាគារភ្នំពេញ។ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | - ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានអញ្ជើញចុះពិនិត្យទីតាំងសំណង់អគារមជ្ឈមណ្ឌលស្តាយុវនីតិសម្បទា នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។<br>- ក្រុមការងារអន្តរក្រសួង (ក្រុមការងាការពារជនរងគ្រោះ) ដែលដឹកនាំដោយ ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ចុះពិនិត្យការគ្រប់គ្រងស្ថានភាពការទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលវិលត្រឡប់តាមច្រកព្រំដែនអន្តរជាតិ និងច្រកតំបន់នៃខេត្តកោះកុង។<br>- បានរៀបចំកិច្ចប្រជុំ ត្រួតពិនិត្យ វាយតម្លៃលទ្ធផលការងារ និងលើកទិសដៅអនុវត្តបន្តរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ។ |

| | |
|---|---|
| | - បានចូលរួមកិច្ចប្រជុំ ស្តីពីគ្រោងកំណត់អត្តសញ្ញាណ និងសមាហរណកម្មជនរងគ្រោះ រវាងអង្គការតនៈអន្តរជាតិ ជាមួយមជ្ឈមណ្ឌលប៉ោយប៉ែត នៅខេត្តបន្ទាយមានជ័យ។<br>- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយអនុសាសន៍នៃវេទិកាអាស៊ាន ស្តីពីទេសន្តរប្រវេសន៍ការងារលើកទី១៣ នៅសណ្ឋាគារភ្នំពេញ។<br>- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងករណីជនរងគ្រោះដល់មន្ត្រី ស.អ.យ ក្រុង ស្រុក ក្នុងខេត្តកំពង់ធំ នៅសណ្ឋាគារកំពង់ធំផាលែស ដោយមានការគាំទ្រពីអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ។<br>- បានសហការជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ បើកវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញទ្វេភាគី រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ លើការគ្រប់គ្រងការអនុវត្តនីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច នៅសណ្ឋាគារសោម៉ាទេវី ខេត្តសៀមរាប។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៣៧លើក អ្នកចូលរួមសរុបចំនួន ១.៤០៥នាក់ (ស្រី ៣១៩នាក់)** | |
| **ខេត្តកណ្តាល** | - ក្រុមការងារក្រុង-ស្រុក បានប្រជុំប្រចាំខែធ្នូ ចំនួន០៧លើក អ្នកចូលរួមចំនួន២១៥នាក់ ស្រី១១៨នាក់។ |
| **ខេត្តសៀមរាប** | - បានរៀបចំកិច្ចប្រជុំ ស្តីពីការត្រៀមប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សចំនួន០១លើក អ្នកចូលរួមចំនួន១៥នាក់ ស្រី០៥នាក់។<br>- បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២១ ចំនួន០១លើក អ្នកចូលរួមចំនួន១៨០នាក់ ស្រី៥៩នាក់។<br>- បានរៀបចំកិច្ចប្រជុំនៅថ្នាក់ខេត្តប្រចាំខែកុម្ភៈចំនួន០១លើក អ្នកចូលរួមចំនួន៥៣នាក់ ស្រី៣១នាក់។<br>- បានដឹកនាំកិច្ចប្រជុំរបស់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង ស្រុក ចំនួន០៨លើក អ្នកចូលរួមចំនួន២០៧នាក់ ស្រី៨១នាក់។ |
| **ខេត្តត្បូងឃ្មុំ** | - លេខាធិការដ្ឋា គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំពិភាក្សាលើការងារ ពង្រឹងតួនាទី ភារកិច្ច រចនាសម្ព័ន្ធ របៀបរបបធ្វើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ |
| **ខេត្តកំពង់ចាម** | - លេខាធិការដ្ឋាខេត្ត ប្រជុំពង្រឹងសមត្ថភាពដល់មន្ត្រីយន្តការនៃ គ.ខ.ប.ជ ចំនួន១៦លើក អ្នកចូលរួមចំនួន៧០២នាក់។ |
| **ខេត្តឧត្តរមានជ័យ** | - រៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់លើកិច្ចការស្ត្រី និងកុមារ ចំនួន០១លើក អ្នកចូលរួមចំនួន១២នាក់ ស្រី០៩នាក់។<br>- រៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលើកទិសដៅអនុវត្តបន្ត ឆ្នាំ២០២១ ចំនួន០១លើក អ្នកចូលរួមចំនួន២១នាក់ ស្រី១៦នាក់។<br>- បានចូលរួមកិច្ចប្រជុំពិភាក្សាលើការអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការ ស្តីពីការការពារក្តីស្ត្រី និងក្មេងស្រី រងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅទីស្តីការក្រសួងកិច្ចការនារី។ |